# វិទ្យាស្ថានព្រេសប៊ីធេរានកម្ពុជា

# ការជ្រើសរើសនិស្សិតថ្មីឲ្យចូលសិក្សាឆ្នាំ2022-2023

## Soli Deo Gloria!

អាសយដ្ឋាន : #316, St 68 K, Phum Preysala, Sangkat Kakab, Khan Posernchey, Phnom Penh

វិទ្យាស្ថានព្រេសប៊ីធេរានកម្ពុជា ការិយាល័យកិច្ចការសិក្សា និងការចូលរៀន ៖ www.cpti.edu.kh

ទូរសព្ទៈ សីហា (092-565-285) / លី យុនស៊ូ (012-682-030) / ហាន អ៊ូស៊ូ(017-883-011)

## ១. សិទ្ធិក្នុងការដាក់ពាក្យ និង មុខវិជ្ជាសិក្សា

បេក្ខជនដែលបានទទួលជ្រមុជទឹកលើសពី១ឆ្នាំ ហើយទទួលការសិក្សារៀនសូត្រពីការដឹកនាំដ៏ល្អរបស់បេសកជន។ សិស្សអាចដាក់ពាក្យចូលរៀនផ្នែក ទេវវិទ្យា(Theology ហៅកាត់ថា Th) ការអប់រំគ្រីស្ទាន (Christian Education ហៅកាត់ថា C.E) ដន្ត្រីសំរាប់ក្រុមជំនុំ(Church Music ហៅកាត់ថាC.M) និង ការបណ្តុះបណ្តាលគ្រូមតេយ្យ(Early Childhood Education ហៅកាត់ថា E.C.E) ។

## ២. វគ្គសិក្សា

### ១) វគ្គសិក្សាបរិញ្ញាបត្រពេញម៉ោង

បេក្ខជនដែលឆ្លងកាត់ការប្រលងជាប់ថ្នាក់ទី១២ អាចចូលរៀនបរិញ្ញាបត្រទេវវិទ្យា (B.Th, B.A) ដែលទទួលស្គាល់ដោយក្រសួងធម្មការនិងសាសនា និង សមាគមន៍ទេវវិទ្យាអប់រំអាស៊ី(ATEA)។ និស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រទូទៅ អាចចូលវគ្គសិក្សាផ្នែក អនុបណ្ឌិតនៃការគង្វាល(M.Div) និង អនុបណ្ឌិតនៃតន្ត្រី(M.A)។និស្សិតដែលមានអំណោយទានជាសាស្រ្តាចារ្យ បន្ទាប់ពីបញ្ចប់ផ្នែក M.Div អាចរៀនវគ្គសិក្សាផ្នែក ទេវវិទ្យានៃបេសកកម្ម(Th.M)។ កំណត់ចំណាំថា វគ្គសិក្សាទាំងអស់បង្រៀនជាភាសាខ្មែរ លើកលែងតែវគ្គសិក្សាផ្នែក Th.M ត្រូវបានបង្រៀនជាភាសាអង់គ្លេស និង ភាសាខ្មែរ ។

### ២) វគ្គសិក្សាកំរិតសញ្ញាបត្រទេវវិទ្យា

ចំពោះសិស្សដែលបានបញ្ចប់ការសិក្សានៅថ្នាក់ទី១០ នោះអាចចូលសិក្សាថ្នាក់ឌីប្លូម៉ា(Diploma) ដែលមានកម្មវិធីសិក្សាដូចគ្នាទៅនឹងថ្នាក់ B.TH និង B.A ដែរ) និង កម្មវិធីហ្វឹកហ្វឺនគ្រូគង្វាល(PTP)។ វគ្គសិក្សាហ្វឹកហ្វឺនគ្រូគង្វាល គឺជាវគ្គសិក្សាសម្រាប់និស្សិតដែលបញ្ចប់ថ្នាក់ឌីប្លូម៉ា(Diploma) ពីវិទ្យាស្ថានរបស់យើង ឬបានបញ្ចប់ការសិក្សារយៈពេល៣ឆ្នាំពីសាលាព្រះគម្ពីរផ្សេង ហើយបានបម្រើពួកជំនុំក្នុងការងារជាគ្រូគង្វាលរយៈពេល៥ឆ្នាំឡើងទៅ។

### ៣) ដំណើរការផ្ទេរឈ្មោះចូលរៀន

និស្សិតដែលផ្ទេរឈ្មោះ នោះត្រូវទទួលការប្រលងចូលរៀនដូចនិស្សិតថ្មីដែរ។ បន្ទាប់ពីប្រលងជាប់ហើយ នោះវិទ្យាស្ថាននឹងទទួលស្គាល់ពិន្ទុមួយផ្នែក ក្នុងករណីដែលភ្ជាប់មកជាមួយព្រឹត្តិបត្រពិន្ទុដែលទទួលបានពីសាលាព្រះគម្ពីរផ្សេង។

❖ ខ្លឹមសារលម្អិត សូមមើលក្នុងតារាងខាងក្រោម៖

# តារាងអំពីវគ្គសិក្សា និង លក្ខខ័ណ្ឌដាក់ពាក្យ

| | វគ្គជ្រើសរើស | ឆ្នាំសិក្សា | លក្ខខ័ណ្ឌដាក់ពាក្យ |
|---|---|---|---|
| ថ្នាក់មហាវិទ្យាល័យ | បរិញ្ញបត្រទេវវិទ្យា(B.Th) និង បរិញ្ញាបត្រអប់រំគ្រីស្ទបរិស្ទ(B.CE) និង បរិញ្ញាបត្រគន្ត្រីពួកជំនុំ(B.C.M) | ៤ឆ្នាំ | សិស្សមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ |
| ថ្នាក់ឯកទេស | ឌីប្លូម៉ា(Diploma) | ៤ឆ្នាំ | សិស្សដែលបញ្ចប់ថ្នាក់ទី១០ឡើងទៅ |
| | ថ្នាក់បណ្តុះបណ្តាលគ្រូមតេយ្យ (E.C.E) សិក្សាពេលរសៀល | ២ឆ្នាំ | សិស្សបញ្ចប់ថ្នាក់ទី១២(អាចមានសំនួរដោយឡែកនៅពេលប្រលង) |
| | ថ្នាក់ហ្វឹកហ្វឺនគ្រូគង្វាល(PTP) | ៣ឆ្នាំ | អ្នកដែលបញ្ចប់ថ្នាក់ឌីប្លូម៉ាផ្នែកទេវវិទ្យា (Diploma) |
| កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ | ថ្នាក់អនុបណ្ឌិតនៃការគង្វាយ (M.Div) | ៣ឆ្នាំ | អ្នកដែលបញ្ចប់មហាវិទ្យាល័យ៤ឆ្នាំ |
| | ថ្នាក់អនុបណ្ឌិតគន្ត្រីក្រុមជំនុំ (M.C.M) | ២ឆ្នាំ | អ្នកដែលបញ្ចប់មហាវិទ្យាល័យផ្នែកគន្ត្រី |
| | ថ្នាក់អនុបណ្ឌិតទេវវិទ្យា(Th.M in Missiology) | ២ឆ្នាំ | អ្នកបញ្ចប់ថ្នាក់M.Div |

## ៣. ពត៌មានអំពីការធ្វើតេស្តចូលរៀន និង កាលវិច្ឆេទ

### ១) កាលបរិច្ឆេទចែកពាក្យសុំចូលរៀន និង ថ្ងៃផុតកំណត់ការដាក់ពាក្យចូលរៀន

- ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២

- លោកអ្នកអាចទាញយកពាក្យសុំចូលរៀនពីគេហទំព័ររបស់វិទ្យាស្ថាន(cpti.edu.kh) ហើយបំពេញដើម្បីដាក់ពាក្យ(ថ្លៃដាក់ពាក្យ10$)

- ឯកសារដាក់ពាក្យ៖ ពាក្យសុំចូលរៀន(ទម្រង់ឯកសាររបស់វិទ្យាស្ថាន) សញ្ញាបត្របញ្ចប់ការសិក្សាខ្ពស់បំផុត(សញ្ញាបត្របញ្ជាក់ការសិក្សាចំពោះថ្នាក់បរិញ្ញាបត្រ ត្រូវដាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ) លិខិតពិនិត្យសុខភាព(ទម្រង់ឯកសាររបស់វិទ្យាស្ថាន) សៀវភៅគ្រួសារ(ច្បាប់ចម្លង) អត្តសញ្ញាណបណ្ណ(ច្បាប់ចម្លង)(អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ) ពាក្យស្នើរសុំចូលរៀននៅវិទ្យាស្ថានទេវវិទ្យាព្រេសប៊ីធេរានកម្ពុជា(ចំពោះថ្នាក់ M.Div ឬ PTP)។

**២) ការណែនាំការប្រលងលើកទី១**

- ថ្នាក់៖ M.Div, PTP

- កាលបរិច្ឆេទ៖ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២២ ម៉ោង៨:៣០ (លទ្ធផលចេញនៅថ្ងៃទី៧ ខែតុលា)

- មុខវិជ្ជាប្រលងចូល៖ ព្រះគម្ពីរ ភាសាអង់គ្លេស សំនួរចម្លើយខ្លីគោលលទ្ធិគ្រីស្ទាន និងសំភាសន៍។

(សូមមើលតារាងសម្រាប់ពត៌មានលំអិត)

- ❖ វគ្គសិក្សានេះគឺបណ្តុះបណ្តាលដើម្បីឲ្យក្លាយជាគ្រូគង្វាល អ្នកប្រលងជាប់ត្រូវតែចូលរួមរៀនវគ្គសិក្សាភាសាក្រិក រយៈពេល៤អាទិត្យ។

**៣) ការណែនាំការប្រលងលើកទី២**

- ថ្នាក់៖ B.Th., Dip(in Theo), B.C.M., B.C.E. E.C.E., M.C.M., Th.M, ការផ្ទេរនិស្សិតថ្នាក់បរិញ្ញាបត្រ

- កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០២២(លទ្ធផលចេញនៅថ្ងៃទី១ ខែធ្នូ)

- មុខវិជ្ជាប្រលងចូល៖ ព្រះគម្ពីរ ភាសាអង់គ្លេស និងសំភាសន៍។(សូមមើលតារាងសម្រាប់ពត៌មានលំអិត)

**៤) មុខវិជ្ជាប្រលង**

- ទូទៅ៖ ភាសាអង់គ្លេស ព្រះគម្ពីរ និងសំភាស៍

- M.Div, PTP : សំនួរចម្លើយខ្លីគោលលទ្ធិគ្រីស្ទាន

- ថ្នាក់តន្ត្រីពួកជំនុំ៖ ការអនុវត្ត(ឧបករណ៍ភ្លេង ឬការប្រើប្រាស់សម្លេង។ (សូមមើលតារាងសម្រាប់ពត៌មានលំអិត)

- កាលបរិច្ឆេទចូលរៀន ៖ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២

**៥) ការចំណាយទាំងអស់**

- ថ្លៃដាក់ពាក្យ៖ $10 (លោកអ្នកអាចទាញយកពាក្យសុំចូលរៀនពីគេហទំព័ររបស់វិទ្យាស្ថាន ហើយបំពេញ រួចយកមកដាក់នៅវិទ្យាស្ថាន)

- ថ្លៃចុះឈ្មោះចូលរៀន៖ $20

- ការពិនិត្យសុខភាព៖ $15(ថ្លៃប្រើប្រាស់នៅមន្ទីរពេទ្យ ហេប្រុន)

- ថ្លៃសិក្សា១ត្រីមាស(១ឆ្នាំមាន៣ត្រីមាស) ៖ $150(នៅពេលបង់តាមត្រីមាស ឬតាមខែ ត្រូវមានសំណើរសុំពីគ្រូគង្វាល ឬបេសកជនទទួលបន្ទុក)

- ថ្លៃស្នាក់នៅ១ត្រីមាស៖ $50

- បន្ទាប់ពីប្រលងជាប់ និស្សិតថ្នាក់បរិញ្ញាបត្រទាំងអស់ ដើម្បីចូលរួមថ្នាក់ភាសាអង់គ្លេសរបស់ខ្លួនអាចត្រូវបង់ថ្លៃសិក្សាតិចតួច ដែលអាចទទួលការវាយតំលៃពិន្ទុភាសាអង់គ្លេស ។

**៦) លិខិតវាយតំលៃនៃអ្នកគង្វាល**

- វគ្គសិក្សា M.Div និង PTP គឺជាវគ្គសិក្សាដែលហ្វឹកហ្វឺនអ្នកគង្វាល និស្សិតត្រូវមានការព្រមទទួលសិស្សឲ្យចូលរៀនពីក្រុមព្រឹក្សាចាស់ទុំ ដូច្នេះនិស្សិតត្រូវភ្ជាប់បន្ថែមកនូវលិខិតបញ្ជាក់ដែលចេញពីសមាគមគណៈព្រឹក្សាចាស់ទុំពួកជំនុំព្រេសប៊ីធេរានកម្ពុជា(PPCC)។

- ករណីនិកាយផ្សេង គឺត្រូវការលិខិតអនុញ្ញាត ដែលមានទំនាក់ទំនងជាមួយនឹងការអប់រំខាងទេវវិទ្យារបស់អ្នកទទួលខុសត្រូវនៅក្នុងនិកាយនោះ។

## ៤. អត្ថប្រយោជន៍ផ្សេងៗ

① បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាស្ថានយើងហើយ នោះនិស្សិតអាចធ្វើសកម្មភាពជាគ្រូផ្សាយដំណឹង ល្អ ឬគ្រូគង្វាលរបស់និកាយព្រេសប៊ីធេរាន(PPCC) តាមរយៈដំណើរការដែលនិកាយនេះកំណត់ឲ្យ។

② មានប្រព័ន្ធអាហាររូបករណ៍សម្រាប់និស្សិតឆ្នើម និង និស្សិតដែលធ្វើការងារសម្រាប់សាលា។

③ សិស្សដែលផ្ទេរចូល បន្ទាប់ពីប្រលងជាប់ការប្រលងចូលរៀនហើយ បើមានភ្ជាប់មកជាមួយនូវព្រឹត្តិបត្រពិន្ទុពីសាលាផ្សេង នោះវិទ្យាស្ថានយើងអាចទទួលស្គាល់នូវពិន្ទុផ្នែកខ្លះដែលសាលាផ្សេងនោះចេញឲ្យ។

❖ ការប្រលងដំណើរការទៅដោយមានគម្លាតពីគ្នា។ អ្នកចូលរួមម្នាក់ៗត្រូវពាក់ម៉ាស់ ហើយអ្នកណាដែលមានគ្រុនក្តៅ មិនត្រូវបានអនុញ្ញាតឲ្យចូលបន្ទប់ប្រលងឡើយ។ ករណីដែលមានកំដៅលើសពី៣៧.៨ សង្ស្យាសេ នោះសូមទាក់ទងមកកាន់វិទ្យាស្ថានជាមុន។

❖ លំដាប់លំដោយ

១) បន្ទាប់ពីបានទាញយកពាក្យសុំចូលរៀន(www.cpti.edu.kh)ហើយ សូមព្រីន និង សរសេរបំពេញ រួចហើយរៀបចំឯកសារដាក់ពាក្យ និង បញ្ជូនមកវិទ្យាស្ថាន ទេវវិទ្យាព្រេសប៊ីធេរានកម្ពុជា(ត្រូវដាក់លិខិតវាយតម្លៃអ្នកជួយឧបត្ថម្ភក្នុងស្រោមសំបុត្របិតជិត រួចបញ្ជូនមក ថ្លៃទទួលឯកសារ $10 ក្នុងដំណើរការដាក់ពាក្យបេក្ខជនចាំបាច់ត្រូវជួបមុខផ្ទាល់ជាមួយអ្នកទទួលខុសត្រូវរបស់សាលា)។

២) បន្ទាប់ពីប្រលងរួចហើយ ដំណើការចុះឈ្មោះធ្វើឡើងទៅតាមលទ្ធផលប្រលង (មកទទួលលិខិតអនុញ្ញាតឲ្យចូលរៀន និង បង់ថ្លៃចំណាយ)។

## ការផ្តល់ពន្ទុ កាលបរិច្ឆេទប្រលង ការប្រកាសលទ្ធផល និង ថ្ងៃផុតកំណត់ចុះឈ្មោះ

| ថ្នាក់ | ពិន្ទុមុខវិជ្ជាប្រលង | ថ្ងៃប្រលង | ថ្ងៃចេញលទ្ធផលនិង ចុះឈ្មោះ |
|---|---|---|---|
| M.Div, P.T.P | ព្រះគម្ពីរ(៤០ពិន្ទុ) សំនួរចម្លើយខ្លី គោលលទ្ធិគ្រីស្ទាន(២០ពិន្ទុ) ភាសាអង់គ្លេស(២០ពិន្ទុ) សំភាសន៍(២០ពិន្ទុ) | ថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០២២ ម៉ោង០៨:៣០ ព្រឹក | ថ្ងៃទី២០ ខែតុលា (ចេញលទ្ធផល) ថ្ងៃទី២៨ ខែតុលា (ផុតកំណត់ការចុះឈ្មោះ ចូលរៀន) |
| Th.M | ការយល់អំពីការអានភាសាអង់គ្លេស (៥០ពិន្ទុ)សំភាសន៍(៥០ពិន្ទុ) | ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ ម៉ោង០៨:៣០នាទី ព្រឹក | ថ្ងៃទី១៥ ខែធ្នូ (ចេញលទ្ធផល) ថ្ងៃទី២៣ ខែធ្នូ(ផុតកំណត់ការចុះឈ្មោះចូលរៀន) |
| B.A. in C.E., (B.C.M, B.Th) | ព្រះគម្ពីរ(៥០ពិន្ទុ) អង់គ្លេស(៣០ពិន្ទុ) សំភាសន៍(២០ពិន្ទុ) | | |
| M.C.M. | សំភាសន៍(២០ពិន្ទុ) ការអនុវត្តន៍(៨០ពិន្ទុ) | | |
| B.Th | ព្រះគម្ពីរ(៥០ពិន្ទុ) ភាសាអង់គ្លេស(៣០ពិន្ទុ) សំភាសន៍(២០ពិន្ទុ) | | |
| B.C.M. | ព្រះគម្ពីរ(៣០ពិន្ទុ) ភាសាអង់គ្លេស(២០ពិន្ទុ) សំភាសន៍(១០ពិន្ទុ) | | |

| | | | |
|---|---|---|---|
| | ការអនុវត្តន៍(៤០ពិន្ទុ) | | |
| E.C.E | ព្រះគម្ពីរ(៥០ពិន្ទុ)<br>ភាសាអង់គ្លេស(៣០ពិន្ទុ)<br>សំភាសន៍(២០ពិន្ទុ) | | |

❖ ការប្រលងការអនុវត្តន៍តន្ត្រីៈ វង់តន្ត្រី ឬ ព្យាណូ(តន្ត្រីបុរាណ សរសើរដំកើង ឬ តន្ត្រីគ្រីស្ទានសម័យទំនើបជ្រើសរើសយក១បទខ្លួនឯង លេងដោយការចងចាំ) ដូតន្ត្រី(តន្ត្រីបុរាណ សរសើរដំកើង ឬ តន្ត្រីគ្រីស្ទានសម័យទំនើប ជ្រើសរើស១បទខ្លួនឯង ច្រៀងដោយការចងចាំ)។

❖ សម្រាប់ពត៌មានបន្ថែម នោះសូមទំនាក់ទំនងមកអ្នកទទួលខុសត្រូវទទួលពាក្យឈ្មោះ សីហា(092-565-285 ជាភាសាខ្មែរ) ឬបេសកជន លី យុនស៊ូ(012-682-030 ជាភាសាកូរ៉េ និង ភាសាខ្មែរ) រៀងរាល់ម៉ោងធ្វើការ(ថ្ងៃច័ន្ទ ដល់ សុក្រ ម៉ោង៩ៈ០០ព្រឹក ដល់ ៥ៈ០០ល្ងាច)។ ប្រសិនបើលោកអ្នកចង់មកសាកសួរពត៌មាននៅវិទ្យាស្ថាន នោះសូមទាក់ទងមកយើងខ្ញុំជាមុន ព្រោះយើងខ្ញុំអាចនឹងមិននៅកន្លែងធ្វើការ ដោយសារភារកិច្ចផ្ទាល់ខ្លួន។

**វិទ្យាស្ថានព្រេសប៊ីធេរានកម្ពុជា អគ្គនាយក គីម ដេហូ**

**ព្រឹទ្ធបុរសកម្មវិធីសិក្សា គ្រូគង្វាល ហាន អ៊ូស៊ូ**